# បូណារទៅតុលាការ



# បូណា ទៅតុលាការ

HAGAR
the whole journey



រឿងរ៉ាវអាក្រក់បានកើតឡើងចំពោះ បូណា ។ នគរបាលបានពិនិត្យមើលបញ្ហា ដើម្បីស្វែងរកថាតើអ្វីត្រូវបានកើតឡើង និងថាតើអ្នកណាម្នាក់បានបំពានច្បាប់ ។ ពេលនេះ បូណា នឹងទៅតុលាការដើម្បីឱ្យគាត់អាចប្រាប់ចៅក្រមអំពីអ្វីដែលបានកើតឡើង ។ ដូចអ្នកដូច្នោះដែរ!





បូណា មានអារម្មណ៍ភ័យខ្លាចបន្តិចបន្តួច ពីព្រោះគាត់មិនដែលទៅតុលាការពីមុនមកឡើយ ។ តើអ្នកអាចគូរពីអារម្មណ៍របស់អ្នកដែលកំពុងកើតឡើងដែរឬទេ? ប៉ុន្តែបន្ទាប់មក បូណា បានចាំថា មានមនុស្សជាច្រើននឹងជួយគាត់នៅក្នុងរឿងនេះ ។ មនុស្សទាំងនេះនឹងធ្វើឱ្យ បូណា មានសុវត្ថិភាព ។



តុលាការគឺមានអគារដ៏ធំមួយដែលមានបន្ទប់ជាច្រើន ។ បូណា នឹងចូលទៅក្នុងបន្ទប់មួយដែលចៅក្រម និងមនុស្សផ្សេងទៀតមួយចំនួននឹងជជែកអំពីរឿងក្ដីនៅទីនោះ ។





ជាចុងក្រោយ ថ្ងៃនោះបានមកដល់ នៅពេលដែល បូណា ត្រូវទៅតុលាការ ។ នៅពេល បូណា បានទៅដល់តុលាការ គាត់ត្រូវរង់ចាំមួយសន្ទុះ ។ គាត់ព្រួយបារម្ភបន្តិចបន្តួច ប៉ុន្តែមនុស្សជាច្រើន ដូចជា បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ដែលបាននិងកំពុងជួយគាត់ កំពុងអង្គុយនៅក្បែរគាត់ ខណៈពេលដែលគាត់រង់ចាំ ដូច្នេះគាត់មានអារម្មណ៍ប្រសើរជាងមុន ។



នៅពេលដល់វេនរបស់ បូណា ត្រូវឆ្លើយសំណួរនៅក្នុងសាលសវនាការ មនុស្សម្នាក់បានមកជួបគាត់ ។

បន្ទាប់មក បូណា ត្រូវបាននាំចូលទៅក្នុងសាលសវនាការ ដើម្បីឱ្យចៅក្រមព្រះរាជអាជ្ញា និងមេធាវីអាចសួរគាត់អំពីអ្វីដែលបានកើតឡើង ។





បូណា មានអារម្មណ៍ភ័យខ្លាចបន្តិចបន្តួច ចំពោះការឃើញជនជាប់ចោទនៅ ក្នុងតុលាការ ។ ប៉ុន្តែ មេធាវីរបស់គាត់បានស្នើឱ្យចៅក្រមដាក់របាំងដើម្បីកុំឱ្យ ជនជាប់ចោទអាចមើលឃើញ បូណា ។ បូណា មានអារម្មណ៍ប្រសើរឡើងច្រើន!



ដំបូង ចៅក្រមបានសួរទៅ បូណា នូវសំណួរមួយចំនួន ។ បន្ទាប់មកព្រះរាជអាជ្ញាបានសួរ បូណា នូវសំណួរមួយចំនួន ។ ហើយបន្ទាប់មក មេធាវីបានសួរទៅ បូណា នូវសំណួរមួយចំនួន ។

សំណួរខ្លះមានភាពងាយស្រួល ដូចជា “ បូណា តើអ្នកមានអាយុប៉ុន្មាន?” ប៉ុន្តែសំណួរខ្លះទៀតមានភាពពិបាកជាងនេះ ពីព្រោះ បូណា ត្រូវតែចងចាំអំពីរឿងរ៉ាវដែលបានកើតឡើងមួរយៈពេលកន្លងមក ។ វាបានធ្វើឱ្យ បូណា មានអារម្មណ៏មិនសប្បាយចិត្តក្នុងការនិយាយអំពីរឿងរ៉ាវទាំងនេះ ប៉ុន្តែ បូណាបានដឹងថា វាជាការសំខាន់ដែលចៅក្រមបានស្តាប់នូវការពិត ។






ដូច្នេះ បូណា បានឆ្លើយសំណួរ ដោយប្រាប់ពីការពិត ។ នៅពេលគាត់មិនយល់នូវសំណួរគាត់គ្រាន់តែនិយាយថា “ខ្ញុំមិនយល់នូវសំណួរនេះទេ” ហើយសំណួរនោះត្រូវបានសួរតាមរបៀបផ្សេងមួយទៀតដែលធ្វើឱ្យ បូណា អាចយល់បាន ។

ឬប្រសិនបើ បូណា មិនចាំចម្លើយទេនោះ គាត់គ្រាន់តែនិយាយថា “ខ្ញុំមិនចាំទេ” ហើយនោះក៏មិនអីដែរ ។



បូណា បានដឹងថា វាជាការសំខាន់ដែលមិនត្រូវឆ្លើយស្មានចំពោះសំណួរណាមួយ ហើយឆ្លើយនូវសំណួរណាដែលគាត់យល់នូវសំណួរ ហើយគាត់ដឹងនូវចម្លើយតែប៉ុណ្ណោះ ។





ខណៈដែល បូណា កំពុងឆ្លើយសំណួរ គាត់ចាំបាច់អាចត្រូវប្រើប្រាស់បន្ទប់ទឹក! បូណា បានស្នើសុំទៅចៅក្រមថាតើគាត់អាចឈប់មួយភ្លែត ដើម្បីប្រើបន្ទប់ទឹកបានដែរឬទេ ។ ដូច្នេះ ពួកគេបានឈប់ ។



នៅពេលមួយនោះ បូណា មានអារម្មណ៍អស់កម្លាំង ។ គាត់បានឆ្លើយសំណួរអស់រយៈពេលដ៏យូរ1 ដូច្នេះ បូណា គ្រាន់តែស្នើសុំចៅក្រមថាតើគាត់អាចសម្រាកបានឬទេ ពីព្រោះគាត់អស់កម្លាំង ។ ហើយនោះមិនអីទេ! បូណា អាចសម្រាកបាន ។





បន្ទាប់មក វាក៏ចប់! បូណា បានធ្វើកិច្ចការដ៏មានសារៈសំខាន់ខ្លាំងមួយ ដោយឆ្លើយសំណួរយ៉ាងស្មោះត្រង់ ។



ក្រោយពីសវនាការតុលាការ ចៅក្រមបានពិចារណាអំពីរឿងរ៉ាវទាំងអស់ដែលពួកគេបានស្តាប់នៅក្នុងសាលសវនាការ ។





ក្រោយពីពិចារណាអំពីរឿងរ៉ាវអស់មួយសន្ទុះមក ចៅក្រមនឹងធ្វើសេចក្តីសម្រេចអំពីអ្វីដែលនឹងកើតឡើងចំពោះជនជាប់ចោទ ។



បូណា មិនដឹងថាតើអ្វីនឹងត្រូវកើតឡើងបន្ទាប់ឡើយ ប៉ុន្តែគាត់ដឹងថា
មាន មនុស្សជាច្រើនដែលចង់ឱ្យ បូណា មានសុវត្ថិភាព និងសប្បាយចិត្ត!
តើអ្វីធ្វើឱ្យអ្នកសប្បាយចិត្ត? គូររឿងរ៉ាវទាំងនោះមួយចំនួននៅទីនេះ!

HAGAR
the whole journey

unicef
unite for children

